# នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 29-Mar-2013, 11:25
CMS/CFO: Uch Arun

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

ភាគីដាក់ឯកសារ៖ លោក **ខៀវ សំផន**

ដាក់ជូន៖ អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម៖ **បារាំង**

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០១៣

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង៖ **សម្ងាត់/Confidential**

ប្រភេទនៃចំណាត់ថ្នាក់៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន៖ **សាធារណៈ/Public**

ឈ្មោះមន្ត្រីទទួលបន្ទុកផ្នែកសំណុំរឿង និងឯកសារ៖

ហត្ថលេខា៖

---

**បណ្ដឹងសាទុក្ខទាន់ៗរបស់មេធាវីការពារក្ដីលោក ខៀវ សំផន ប្រឆាំងនឹងសេចក្ដីសម្រេច ចេញតាមរយៈអ៊ីម៉ែលរបស់លោកស្រី Susan LAMB នៅថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៣**

---

| ដាក់ដោយ៖ | ដាក់ជូន៖ |
|---|---|
| **មេធាវីការពារក្ដីលោក ខៀវ សំផន** | **អង្គជំនុំជម្រះតុលាការកំពូល៖** |
| មេធាវី គង់ សំអុន | ចៅក្រម គង់ ស្រីម |
| មេធាវី Anta GUISSÉ | ចៅក្រម Agnieszka KLONOWIECKA-MILART |
| មេធាវី Arthur VERCKEN | ចៅក្រម សោម សិរីវឌ្ឍ |
| មេធាវី Jacques VERGÈS | ចៅក្រម Chandra Nihal JAYASINGHE |

**ជំនួយការ៖**
លោកស្រី សេង សុជាតា
កញ្ញា Marie CAPOTORTO
កញ្ញា Shéhérazade BOUARFA
កញ្ញា Mathilde CHIFFERT
កញ្ញា អ៊ូច ស្រីផាត់
លោក Pierre TOUCHE
កញ្ញា Blandine ZELLER
លោកស្រី សុគន្ធ មោនីកា

ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម យ៉ា ណារិន
ចៅក្រម Florence Ndepele Mwachande MUMBA

**សហព្រះរាជអាជ្ញា៖**
លោកស្រី ជា លាង
លោក Andrew CAYLEY

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

**ក្រុមមេធាវីការពារក្តីទាំងអស់**

# គោរពជូនអង្គជំនុំជម្រះតុលាការកំពូល

១. នៅថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ អង្គជំនុំជម្រះតុលាការកំពូលបានប្រកាសមោឃភាពការបំបែកកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីលើសំណុំរឿង ០០២ និងបានកត់សម្គាល់ថាភាគីបានទទួលរងនូវព្យសនកម្មជាច្រើន[1]។

២. នៅថ្ងៃទី ១៨ ថ្ងៃទី ២០ និងថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានបើកសវនាការលើផលវិបាកនៃសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល តាមរយៈការសួរសំណួរទៅកាន់ភាគី[2]។

---

[1] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីវិសាលភាពនៃសំណុំរឿង ០០២/០១ អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារ E163/5/1/13 ("សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលប្រកាសមោឃភាពការបំបែកកិច្ចដំណើរការនីតិវិធី")។ *[មេធាវីការពារក្តីសូមបញ្ជាក់ថា យើងខ្ញុំបានធ្វើការងារ ផ្អែកលើសំណៅបកប្រែជាភាសាបារាំងមិនពេញលេញក្រៅផ្លូវការនៃសេចក្តីសម្រេចនេះ ដែលផ្តល់ជូនដោយអង្គភាពបកប្រែភាសា]*។

[2] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារ E163/5/1/13/1 ("អនុស្សរណៈទី ១ ពាក់ព័ន្ធនឹងសវនាការលើការបំបែកកិច្ចដំណើរការនីតិវិធី") ស្តីពីការណែនាំដល់ភាគីនានាដោយសារតែមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីវិសាលភាពនៃសំណុំរឿង ០០២/០១ (ឯកសារ E163/5/1/13), អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១៣ ("អនុស្សរណៈទី ២ ពាក់ព័ន្ធនឹងសវនាការលើការបំបែកកិច្ចដំណើរការនីតិវិធី") ស្តីពីសំណួរបន្ថែមទៅភាគី ក្រោយសវនាការថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីវិសាលភាពនៃសំណុំរឿង ០០២/០១ (ឯកសារ E163/5/1/13), ប្រតិចារឹកសវនាការ ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារ E1/171.1, ប្រតិចារឹកសវនាការ ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៣ (សំណៅព្រាង), ប្រតិចារឹកសវនាការ ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៣ (សំណៅព្រាង)។ *[សំណៅបកប្រែក្រៅផ្លូវការនៃអនុស្សរណៈទាំងពីរខាងលើនេះជាភាសាបារាំង ត្រូវបានអង្គភាពបកប្រែភាសាផ្តល់ជូនមេធាវីការពារក្តី]*។

៣. នៅថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៣ ពេលឆ្លើយតបទៅនឹងសំណួរមួយក្នុងចំណោមសំណួរទាំងអស់[3] មេធាវីការពារក្តីទាំងបីក្រុមបានស្នើសុំកុំឲ្យអង្គជំនុំជម្រះសាលាដំបូងកោះហៅសាក្សី ឬអ្នកជំនាញ ដរាបណាមិនទាន់ចេញសេចក្តីសម្រេចថ្មីលើវិសាលភាពនៃការជំនុំជម្រះក្តី[4]។

៤. នៅថ្ងៃដដែលនោះ ក្រោយបញ្ចប់សវនាការបានបីម៉ោង ភាគីទទួលបានការជូនដំណឹងតាមអ៊ីម៉ែល របស់មន្ត្រីច្បាប់ជាន់ខ្ពស់ថា អង្គជំនុំជម្រះសាលាដំបូងបានសម្រេចកោះហៅអ្នកជំនាញ Philip SHORT និង Elisabeth BECKER ឲ្យមកផ្តល់សក្ខីកម្មនៅថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៣ គឺមុន ពេលចេញសេចក្តីសម្រេចថ្មីលើវិសាលភាពនៃការជំនុំជម្រះក្តី ("សេចក្តីសម្រេចរងការជំទាស់")[5]។

៥. ថ្ងៃនេះ អនុលោមតាមវិធាន ២១ និងវិធាន ១០៤(៤) នៃវិធានផ្ទៃក្នុង មេធាវីការពារក្តីលោក ខៀវ សំផន ("ម្ចាស់បណ្តឹងសាទុក្ខ") សូមប្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងអ៊ីម៉ែលនេះ ដែលយើងខ្ញុំចាត់ទុក ថាជាសេចក្តីសម្រេច។ យោងទៅលើសារៈសំខាន់ និងភាពបន្ទាន់ នៃបញ្ហាដែលបានលើកឡើង អង្គជំនុំជម្រះតុលាការកំពូលត្រូវសម្រេច ឲ្យបានមុនថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៣ ឬបង្គាប់ឲ្យ ផ្អាកកិច្ចដំណើរការនីតិវិធីលើអង្គសេចក្តី រហូតដល់ពេលចេញសេចក្តីសម្រេចលើបណ្តឹងសាទុក្ខ។ សេចក្តីសម្រេចរងការជំទាស់ត្រូវធ្វើមោឃភាព ពីព្រោះកំហុសរបស់អង្គជំនុំជម្រះធ្វើមោឃភាព សេចក្តីសម្រេចនេះ ហើយបង្កព្យសនកម្មធ្ងន់ធ្ងរមិនអាចជួសជុលបានដល់ម្ចាស់បណ្តឹងសាទុក្ខ។

## I- **<u>ទម្រង់នៃសេចក្តីសម្រេច</u>**

[3] អនុស្សរណៈទី ២ ស្តីពីសវនាការលើការបំបែកកិច្ចដំណើរការនីតិវិធី កថាខណ្ឌ ៣ iii) និង iv)។

[4] ប្រតិចារិកសវនាការ ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៣ (សំណៅព្រាង) ទំព័រ ២៧ បន្ទាត់ ១៨-២៤ ដល់ទំព័រ ២៨ បន្ទាត់ ១-៤, ទំព័រ ៣១ បន្ទាត់ ១, ទំព័រ ៣១ បន្ទាត់ ២៣-២៥ និងទំព័រ ៣២ បន្ទាត់ ១១-១៨, ទំព័រ ៣៧ បន្ទាត់ ៩-១៦។

[5] អ៊ីម៉ែលរបស់លោកស្រី Susan LAMB ផ្ញើជូនភាគី នៅថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៣ វេលាម៉ោង ១៥ និង ១៤ នាទី កម្មវត្ថុ៖ *"សេចក្តីណែនាំដល់ភាគី ក្រោយសវនាការលើការបំបែកកិច្ចដំណើរការនីតិវិធី"* ("សេចក្តីសម្រេចរងការជំទាស់")។ អ៊ីម៉ែលនេះ ត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធ។

៦. យោងតាមយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះតុលាការកំពូល *"សេចក្តីសម្រេចរបស់តុលាការត្រូវតែមានចរិតលក្ខណៈជាលិខិតមានអានុភាពចាប់បង្ខំ។ ក្នុងន័យនេះ សេចក្តីសម្រេចរបស់តុលាការត្រូវចាត់ការលើបញ្ហាអង្គច្បាប់មួយដែលស្ថិតនៅចំពោះមុខខ្លួនឲ្យបានច្បាស់លាស់ ហើយត្រូវមានផ្នែកសម្រេចសេចក្តី ដែលដោះស្រាយបញ្ហាអង្គសេចក្តី ឬបញ្ហានីតិវិធី ដោយបង្កើត កែប្រែ បញ្ចប់ ឬបញ្ជាក់អះអាងនូវទំនាក់ទំនងតាមផ្លូវច្បាប់ ដែលពាក់ព័ន្ធនឹងភាគី"*[6]។

៧. ប៉ុន្តែ អ៊ីមែលរបស់មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ២១ ខែ កុម្ភៈឆ្នាំ ២០១៣ បានចាត់ការយ៉ាងច្បាស់លាស់ទៅលើសំណើរបស់មេធាវីការពារក្តី សុំមិនឲ្យកោះហៅអ្នកជំនាញ ឬសាក្សី ដរាបណាមិនទាន់ចេញសេចក្តីសម្រេចថ្មីលើវិសាលភាពនៃការជំនុំជម្រះក្តី។ អ៊ីមែលនេះយល់ស្របតាមសំណើរបស់មេធាវីការពារក្តី ដោយមិនកោះហៅសាក្សី ប៉ុន្តែ កោះហៅអ្នកជំនាញ Philip SHORT និង Elisabeth BECKER ។

៨. អាស្រ័យហេតុនេះ អ៊ីមែលនេះមានចរិតលក្ខណៈជាលិខិតតុលាការមានអានុភាពចាប់បង្ខំ ទោះបីជាទម្រង់របស់វាមិនផ្លូវការក៏ដោយ។ ដូច្នេះ សុពលភាពរបស់វាត្រូវវាយតម្លៃ ផ្អែកលើ *"ភាពយុត្តិធម៌ ដោយពិចារណាថាតើអត្ថិភាព ខ្លឹមសារ និងផលវិបាកលើកិច្ចដំណើរការនីតិវិធី មានភាពច្បាស់លាស់គ្រប់គ្រាន់ដែរឬទេ"*[7]។

## II- <u>ភាពអាចទទួលយកបាននៃបណ្តឹងសាទុក្ខ និងភាពចាំបាច់ក្នុងការចេញសេចក្តីសម្រេចភ្លាមៗ ឬបន្ទាប់ឲ្យផ្អាកកិច្ចដំណើរការនីតិវិធី</u>

---

[6] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំឲ្យចាត់ការជាបន្ទាន់ តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង, អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១២ ឯកសារ E176/2/1/4 ("សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលពាក់ព័ន្ធនឹងវិធាន ៣៥") កថាខណ្ឌ ២៥, សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលប្រកាសមោឃភាពការបំបែកកិច្ចដំណើរការនីតិវិធី កថាខណ្ឌ ៣០។

[7] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលប្រកាសមោឃភាពការបំបែកកិច្ចដំណើរការនីតិវិធី កថាខណ្ឌ ៣០ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

៩. បណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចរងការជំទាស់ អាចទទួលយកបាន យោងតាមវិធាន ២១ និងវិធាន ១០៤(៤) នៃវិធានផ្ទៃក្នុង។

១. <u>វិធាន ២១ នៃវិធានផ្ទៃក្នុង</u>

១០. បើតាមចៅក្រមអង្គបុរេជំនុំជម្រះនៃ អ.វ.ត.ក *"ភាពយុត្តិធម៌ គឺជាធាតុផ្សំចម្បងដែលត្រូវគិតគូរនៅគ្រប់កិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក ដូចមានចែងក្នុងវិធាន ២១(១)(ក) នៃវិធានផ្ទៃក្នុង"*។ ក្នុងបរិបទនេះ ចៅក្រមអង្គបុរេជំនុំជម្រះយល់ឃើញថា ពេលអង្គហេតុ និងកាលៈទេសៈនៃការប្តឹងឧទ្ធរណ៍តម្រូវ អង្គបុរេជំនុំជម្រះមានសមត្ថកិច្ចពិនិត្យមើលមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍ ដែលមិនមានចែងច្បាស់លាស់ នៅក្នុងវិធានផ្ទៃក្នុង[8]។

១១. ទោះជាយល់ឃើញថាមិនមានសិទ្ធិជាទូទៅក្នុងការប្តឹងសាទុក្ខភ្លាមៗ[9] ក៏ចៅក្រមអង្គបុរេជំនុំជម្រះបានពិនិត្យមើលបណ្តឹងឧទ្ធរណ៍ ជាករណីលើកលែង តាមរយៈការបកស្រាយយ៉ាងទូលំទូលាយនូវសិទ្ធិប្តឹងឧទ្ធរណ៍ ផ្អែកតាមវិធាន ២១[10]។

---

[8] សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារ D427/2/15 ("សាលដីការបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ") កថាខណ្ឌ ៧១។

[9] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីអញ្ញត្រកម្មរបស់លោក អៀង សារី តាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង (គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ និងការលើកលែងទោស និងការអនុគ្រោះទោស) អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១២ ឯកសារ E51/15/1/2 ទំព័រ ៤ សំអាងហេតុចុងក្រោយ។ សាលដីការបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៧៣។

[10] សាលដីការបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៧២, សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ទាក់ទិននឹងការប្រាស្រ័យទាក់ទងការងារជាមួយតែភាគីម្ខាងរបស់មន្ត្រីច្បាប់ជាន់ខ្ពស់ អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១២ ឯកសារ E154/1/1/4 កថាខណ្ឌ ១៥។

១២. ក្នុងករណីបែបនេះ ចៅក្រមបានពិចារណាយ៉ាងល្អិតល្អន់ថា តើបញ្ហាយុត្តិធម៌ដែលបានលើកឡើង *"មានភាពធ្ងន់ធ្ងរហួសហេតុ និងផលប៉ះពាល់លើកិច្ចដំណើរការនីតិវិធី ដែលជាយុត្តិកម្មឲ្យទទួលយកបណ្តឹងឧទ្ធរណ៍ ដែរឬទេ"*[11]។ ចៅក្រមក៏បានថ្លឹងថ្លែង រវាងសារៈសំខាន់ក្នុងការពន្លឿននីតិវិធី និងការព្រួយបារម្ភអំពីភាពយុត្តិធម៌ តើមួយណាមានប្រៀបជាង។ ក្នុងករណីទីពីរ ការលើកឡើងនូវមូលដ្ឋានបណ្តឹងឧទ្ធរណ៍ដែលបានពិនិត្យ មុនពេលចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ *"គឺជាកត្តាចាំបាច់សម្រាប់ឲ្យអង្គជំនុំជម្រះទទួលយក"*[12]។

១៣. ឥឡូវនេះ អង្គហេតុ និងកាលៈទេសៈនៃបណ្តឹងសាទុក្ខ ទាមទារឲ្យមានការបកស្រាយទូលំទូលាយជាងនេះអំពីសិទ្ធិក្នុងការធ្វើបណ្តឹងសាទុក្ខ ផ្អែកតាមវិធាន ២១ និងតម្រូវឲ្យមានកិច្ចអន្តរាគមន៍ ជាករណីលើកលែង និងជាបន្ទាន់ ពីសំណាក់អង្គជំនុំជម្រះតុលាការកំពូល។

១៤. តាមពិត ភាពធ្ងន់ធ្ងរនៃការព្រួយបារម្ភអំពីភាពយុត្តិធម៌ និងផលប៉ះពាល់របស់វាលើការជំនុំជម្រះក្តីដែលកំពុងប្រព្រឹត្តទៅ ជាមូលហេតុនៃការចេញសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលប្រកាសមោឃភាពការបំបែកកិច្ចដំណើរការនីតិវិធី ដែលបង្គាប់ដោយអង្គជំនុំជម្រះសាលាដំបូង។

១៥. ក៏ប៉ុន្តែ ច្បាស់ណាស់ថា ក្នុងពេលរង់ចាំការចេញដីកាសម្រេចថ្មីលើការបំបែកកិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះសាលាដំបូងប្រព្រឹត្តកំហុសដដែល ដែលបង្កឲ្យមានព្យសនកម្ម។ ប្រសិនបើអង្គជំនុំជម្រះតុលាការកំពូលមិនធ្វើអន្តរាគមន៍ជាបន្ទាន់ទេ ព្យសនកម្មដែលទទួលរងនឹងមិនអាចជួសជុលបានឡើយ។

១៦. ប្រសិនបើបណ្តឹងសាទុក្ខនេះអាចទទួលយកបាន យោងតាមវិធាន ២១ បណ្តឹងសាទុក្ខនេះក៏អាចទទួលយកបាន យោងតាមវិធាន ១០៤(៤) នៃវិធានផ្ទៃក្នុង ផងដែរ។

---

[11] សាលដីការបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៧៣។

[12] សាលដីការបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៧៣ និងកថាខណ្ឌ ៧៥។

## ២. <u>វិធាន ១០៤(៤) នៃវិធានផ្ទៃក្នុង</u>

១៧. យោងតាមវិធាន ១០៤(៤) នៃវិធានផ្ទៃក្នុង *"សេចក្តីសម្រេចស្តីពីការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ តាមវិធាន ៣៥(៦)"* ត្រូវបានបើកផ្លូវឱ្យប្តឹងសាទុក្ខបានភ្លាមៗ។

១៨. វិធាន ៣៥ បង្ហាញ *"ជាឧទាហរណ៍"* អំពីអំពើមួយចំនួនដែលអាចចាត់ទុកថាជាការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់តុលាការ ប៉ុន្តែមិនបានកំណត់អំពើហាមឃាត់ឱ្យបានលម្អិតឡើយ[13]។

១៩. យោងតាមវិធានដដែលនេះ *"<u>ជនណាម្នាក់</u>ដែលជ្រៀតជ្រែកដោយចេតនាពិតប្រាកដ ក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ"*[14] អាចត្រូវបានដាក់ទណ្ឌកម្ម ហើយនៅពេលអង្គជំនុំជម្រះមានហេតុផលជឿថាបុគ្គលណាម្នាក់អាចធ្លាប់បានប្រព្រឹត្តអំពើណាមួយ អង្គជំនុំជម្រះអាច *"ចាត់ការជាមួយបញ្ហានេះជាបន្ទាន់"*។

២០. បើតាមអង្គជំនុំជម្រះតុលាការកំពូល *"គ្មានកំហុសអង្គច្បាប់ ឬអង្គហេតុ គ្មានកំហុសឆន្ទានុសិទ្ធិណាមួយពី សំណាក់អង្គជំនុំជម្រះសាលាដំបូង អាចបង្កើតជាការជ្រៀតជ្រែកដោយចេតនាពិតប្រាកដក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ តាមខ្លឹមសារនៃវិធាន ៣៥ នៃវិធានផ្ទៃក្នុងឡើយ"*[15]។

២១. ម្ចាស់បណ្តឹងសាទុក្ខយល់ឃើញថា ក្នុងករណីច្បាស់លាស់ និងជាក់លាក់បំផុតនេះ កំហុសដែលប្រព្រឹត្តដោយចេតនាពិតប្រាកដរបស់អង្គជំនុំជម្រះសាលាដំបូង នៅក្នុងដំណាក់កាលនេះនៃនិតិវិធីដោយល្មើសនឹងការបញ្ញត្តិរបស់អង្គជំនុំជម្រះតុលាការកំពូល បង្គាប់ឱ្យអង្គជំនុំជម្រះសាលាដំបូងគោរពយុត្តិធម៌ និងសច្ចភាពផ្លូវច្បាប់ គឺជាការជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ

---

[13] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលស្តីពីវិធាន ៣៥ កថាខណ្ឌ ៣៣។

[14] យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម។

[15] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបង្គាប់ឱ្យជនជាប់ចោទមានវត្តមានក្នុងសាលសវនាការ អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១២ ឯកសារ E130/4/3 ទំព័រ ៣ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

ដែលជាយុត្តិកម្មសម្រាប់ឲ្យអង្គជំនុំជម្រះតុលាការកំពូលចាត់ការជាបន្ទាន់។

២២. ជាក់ស្តែង ចៅក្រមអង្គបុរេជំនុំជម្រះបានទទួលស្គាល់រួចហើយថា សញ្ញាណនៃការជ្រៀតជ្រែក ដូចមានចែងនៅក្នុងវិធាន ៣៥ នៃវិធានផ្ទៃក្នុង មានន័យទូលំទូលាយ ហើយមានទំនាក់ទំនងមុខងារ រវាងវិធាន ២១ និងវិធាន ៣៥ នៃវិធានផ្ទៃក្នុង[16]។ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថ្មីៗ កន្លងទៅនេះថា នៅក្នុងរឿងក្តីដែលមានទំហំធំដូចសំណុំរឿង ០០២ ការចាត់ថានន្ទានុសិទ្ធិរបស់ អង្គជំនុំជម្រះគ្មានដែនកំណត់ គឺរំលោភទៅនឹងគោលការណ៍បកស្រាយ ដូចមានចែងនៅក្នុងវិធាន ២១(១) នៃវិធានផ្ទៃក្នុង[17]។

២៣. នេះជាការហាមឃាត់ *"ការខំប្រឹងប្រែងដើម្បីប្រឆាំងនឹងអាណត្តិ និងដំណើរការរបស់តុលាការ"*[18] *"ដោយសារតែអំពើនោះប៉ះពាល់ដល់ធម្មានុរូបភាពរបស់តុលាការ ក្នុងក្រសែភ្នែករបស់ភាគី និង សាធារណជនទូទៅ"*[19]។ អង្គជំនុំជម្រះតុលាការកំពូលកំណត់ជាក់ច្បាស់ និងលម្អិតជាងនេះថា៖

*"វិធាន ៣៥ នៃវិធានផ្ទៃក្នុង ត្រូវបានបង្កើតឡើងជាពិសេស ក្នុងគោលបំណងអនុវត្តវិធានការដាក់ ទណ្ឌកម្ម ដើម្បីធ្វើឲ្យញញើត។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះតុលាការកំពូលយល់ ឃើញថាវិធាន ៣៥ នៃវិធានផ្ទៃក្នុង ក៏បម្រើឲ្យ<u>គោលបំណងទូទៅនៃការជំនុំជម្រះក្តីប្រកបដោយ យុត្តិធម៌ និងប្រសិទ្ធភាពផងដែរ</u>។ ក្នុងន័យនេះ តុលាការមិនត្រឹមតែមាន<u>ករណីយកិច្ច</u>ដាក់ទណ្ឌកម្ម ទៅលើការជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលតុលាការប៉ុណ្ណោះទេ គឺថែមទាំង<u>បញ្ឈប់ការបន្តជ្រៀត ជ្រែក</u> និងបង្ការការជ្រៀតជ្រែកដែលអាចនឹងកើតមាន។ <u>ករណីយកិច្ចនេះកាន់តែមានភាពពាក់ព័ន្ធ នៅពេលការជ្រៀតជ្រែកគំរាមកំហែងដល់សិទ្ធិជាមូលដ្ឋាន ដូចជា សិទ្ធិទទួលបានការជំនុំជម្រះ</u>*

[16] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលស្តីពីវិធាន ៣៥ កថាខណ្ឌ ៣៣ យោងទៅសាលដីកាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងទៅនឹងដីកាសម្រេចលើសំណើលើកទីពីររបស់លោក នួន ជា សុំឱ្យបំពេញកិច្ចស៊ើបសួរ (វិធាន ៣៥) អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០១០ ឯកសារ D384/5/2។

[17] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលប្រកាសមោឃភាពការបំបែកកិច្ចដំណើរការនីតិវិធី កថាខណ្ឌ ៤០។

[18] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលពាក់ព័ន្ធនឹងវិធាន ៣៥ កថាខណ្ឌ ៣៤។

[19] ដូចយោងខាងលើ កថាខណ្ឌ ៣៥។

*ប្រកបដោយយុត្តិធម៌។ ដូច្នេះ វាជាការសមហេតុផលក្នុងការបកស្រាយពីន័យទូលាយដល់ន័យចង្អៀតថា អ.វ.ត.ក អាចប្រើប្រាស់នីតិវិធី ដូចមានចែងក្នុងវិធាន ៣៥ នៃវិធានផ្ទៃក្នុង សំដៅចាត់វិធានការដាក់ទណ្ឌកម្មតាមន័យចង្អៀត និងចាត់វិធានការកែតម្រូវផ្សេងទៀតដែលមិនមានលក្ខណៈដាក់ទណ្ឌកម្ម និងមិនតម្រូវឲ្យបង្ហាញពិរុទ្ធភាព ដើម្បីធានាសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌"*[20]។

២៤. លទ្ធផលនៃការបកស្រាយវិធាននេះ ឆ្លុះបញ្ចាំងយ៉ាងច្បាស់នូវការពិចារណាទៅលើសិទ្ធិជាមូលដ្ឋានទាំងអស់របស់ជនជាប់ចោទ[21]។

២៥. ក្នុងករណីនេះ អំពើរបស់អង្គជំនុំជម្រះសាលាដំបូង ដែលអនុញ្ញាត ជាអាទិ៍ ឲ្យស្តាប់ចម្លើយសាក្សី-អ្នកជំនាញ នៅខណៈដែលមិនទាន់បានកំណត់វិសាលភាពនៃការជំនុំជម្រះក្តី គឺជាការប៉ះពាល់ដល់ធម្មានុរូបភាពរបស់តុលាការ នៅក្នុងក្រសែភ្នែករបស់ភាគី និងសាធារណជនទូទៅ។ អំពើនេះបន្តប្រឆាំងនឹងប្រសិទ្ធភាព និងភាពយុត្តិធម៌នៃនីតិវិធី និងគំរាមកំហែងដល់សិទ្ធិជាមូលដ្ឋានរបស់ម្ចាស់បណ្តឹងសាទុក្ខក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌។ អង្គជំនុំជម្រះតុលាការកំពូលមានករណីយកិច្ចចាត់វិធានការកែតម្រូវ ដើម្បីការពារសិទ្ធិនេះ។

២៦. ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលត្រូវប្រកាសទទួលយកបណ្តឹងសាទុក្ខនេះ និងធ្វើមោឃភាពសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ជាបន្ទាន់។

## III- កំហុសរបស់អង្គជំនុំជម្រះសាលាដំបូង

២៧. នៅពេលចេញសេចក្តីសម្រេចរងការជំទាស់នេះ អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុសអង្គច្បាប់ដែលនាំឲ្យមោឃភាពសេចក្តីសម្រេចនោះ។ លើសពីនេះទៅទៀត សេចក្តីសម្រេចនេះមាន

[20] ដូចយោងខាងលើ កថាខណ្ឌ ៤៥ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[21] សូមមើលសេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ស្តីពីសំណើសុំដោះលែងជាបន្ទាន់ អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារ E50/3/1/4 កថាខណ្ឌ ៣០។

កំហុសជាច្រើនស្តែងចេញពីការប្រើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបង្កឲ្យមានព្យសនកម្មធ្ងន់ធ្ងរមិនអាចជួសជុលបានដល់ម្ចាស់បណ្តឹងសាទុក្ខ។

១. <u>កំហុសអង្គច្បាប់</u>

២៨. អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា នៅពេលសម្រេចបំបែកបទចោទ អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុសដែលនាំឲ្យមោឃភាពការបំបែកនោះ[22]។ ក៏ប៉ុន្តែ អង្គជំនុំជម្រះតុលាការកំពូលបានអនុញ្ញាតឲ្យអង្គជំនុំជម្រះសាលាដំបូងជួសជុលកំហុសរបស់ខ្លួន និងថែមទាំងបានត្រួសត្រាយផ្លូវឲ្យដើរទៀតផង ក្នុងករណីបំបែកកិច្ចដំណើរការនីតិវិធីថ្មី[23]។

២៩. កំហុសទាំងអស់របស់អង្គជំនុំជម្រះសាលាដំបូង ដែលបង្ហាញដោយអង្គជំនុំជម្រះតុលាការកំពូល ត្រូវបានប្រព្រឹត្តពាក់ព័ន្ធនឹងភាពយុត្តិធម៌ និងសច្ចភាពផ្លូវច្បាប់។ ដូច្នេះ ដំបូន្មានរបស់អង្គជំនុំជម្រះតុលាកាកំពូល ក្នុងករណីបំបែកកិច្ចដំណើរការនីតិវិធីថ្មី មានគោលដៅធានាឲ្យបាននូវភាពយុត្តិធម៌ និងសច្ចភាពផ្លូវច្បាប់[24]។

៣០. អង្គជំនុំជម្រះតុលាការកំពូលធ្វើបែបនេះ គឺដោយសារតែអង្គជំនុំជម្រះតុលាការកំពូលទទួលស្គាល់ *"ទំហំ និងសារៈសំខាន់នៃបញ្ហាទូទៅកំពុងប្រឈម"*[25] និងទទួលស្គាល់ថា *"នៅក្នុងរឿងក្តីធំធេង និងស្មុគស្មាញដូចសំណុំរឿង ០០២ ការបំបែកកិច្ចដំណើរការនីតិវិធីមានផលប៉ះពាល់យ៉ាងធំធេង និងខ្លាំងក្លាដោយជៀសពុំរួចដល់ភាគីពាក់ព័ន្ធ"*[26]។

---

[22] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលប្រកាសមោឃភាពការបំបែកកិច្ចដំណើរការនីតិវិធី កថាខណ្ឌ ៤៩ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[23] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលប្រកាសមោឃភាពការបំបែកកិច្ចដំណើរការនីតិវិធី កថាខណ្ឌ ៥០។

[24] ដូចយោងខាងលើ កថាខណ្ឌ ១៧, ២៣, ២៤, ៣៣, ៣៥, ៣៦, ៤០, ៤១, ៤២, ៤៣, ៤៤, ៤៥, ៤៦, ៤៧, ៤៨, ៤៩ និង ៥០។

[25] ដូចយោងខាងលើ កថាខណ្ឌ ៣៦។

[26] ដូចយោងខាងលើ កថាខណ្ឌ ៤០។

៣១. ចាប់ពីពេលអង្គជំនុំជម្រះតុលាការកំពូលចេញសេចក្តីសម្រេចមក អង្គជំនុំជម្រះសាលាដំបូងមានជម្រើសក្នុងការបន្តការជំនុំជម្រះក្តីដែលកំពុងប្រព្រឹត្តទៅ ឬបង្គាប់ការបំបែកកិច្ចដំណើរការនីតិវិធីថ្មី ដោយគោរពតាមការបញ្ញត្តិរបស់អង្គជំនុំជម្រះតុលាការកំពូល។

៣២. ក្នុងករណីបំបែកកិច្ចដំណើរការនីតិវិធីថ្មី យោងតាមទំហំ សារៈសំខាន់ ផលប៉ះពាល់នៃបញ្ហាកំពុងប្រឈមទៅលើភាគីនានា និងការកត់សម្គាល់ឃើញនូវព្យសនកម្មជាច្រើនដែលបង្កឡើងដោយការបំបែកកិច្ចដំណើរការនីតិវិធីលើកដំបូង ច្បាស់ណាស់ថា កិច្ចដំណើរការនីតិវិធីលើអង្គសេចក្តីត្រូវផ្អាកសិន រហូតដល់ពេលចេញសេចក្តីសម្រេចថ្មីលើការបំបែកកិច្ចដំណើរការនីតិវិធី។

៣៣. ក៏ប៉ុន្តែ នៅពេលអង្គជំនុំជម្រះសាលាដំបូងចេញសេចក្តីសម្រេចដែលត្រូវបានប្តឹងសាទុក្ខនេះ ច្បាស់ណាស់ថា អង្គជំនុំជម្រះសាលាដំបូងបានសម្រេចជ្រើសរើសយកការបំបែកកិច្ចដំណើរការនីតិវិធីថ្មីរួចទៅហើយ។ម្យ៉ាងវិញទៀត ចេតនារបស់អង្គជំនុំជម្រះសាលាដំបូងបានស្តែងឡើងយ៉ាងច្បាស់ក្រឡែត នៅពេលធ្វើសវនាកាលើផលវិបាកនៃសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល។ ជាក់ស្តែង សំណួរផ្ញើជូនភាគីសុទ្ធតែតម្រង់ទិសទៅរកការបំបែកកិច្ចដំណើរការនីតិវិធី[27]។ លើសពីនេះទៅទៀត ប្រធានអង្គជំនុំជម្រះសាលាដំបូងបានបញ្ចប់សវនាការ ដែលក្នុងពេលនោះ មេធាវីការពារក្តីពីរក្រុមបានស្នើសុំកុំឲ្យបំបែកបទចោទ ដោយប្រកាសថាអង្គជំនុំជម្រះសាលាដំបូងនឹងចេញសេចក្តីសម្រេច *"ក្នុងពេលសមស្របខាងមុខឲ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន អំពីវិសាលភាពនៃសំណុំរឿង ០០២ សម្រាប់ធ្វើសវនាការនៅដំណាក់កាលដំបូង"*[28]។

៣៤. ទោះជាយ៉ាងណាក៏ដោយ ក្នុងពេលទន្ទឹងរង់ចាំសេចក្តីសម្រេចថ្មីលើការបំបែកកិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះសាលាដំបូងមិនផ្អាកកិច្ចដំណើរការនីតិវិធីលើអង្គសេចក្តីនោះទេ បែរជាសម្រេចស្តាប់សក្ខីកម្មអ្នកជំនាញ Philip SHORT និង Elisabeth BECKER ភ្លាមៗ។ អង្គជំនុំជម្រះសាលា

---

[27] អនុស្សរណៈទី ១ និងទី ២ ស្តីពីសវនាការលើការបំបែកកិច្ចដំណើរការនីតិវិធី។

[28] ប្រតិចារឹកសវនាការ ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៣ (សំណៅព្រាង) ទំព័រ ៤៨ បន្ទាត់ ១៧-២០។ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

ដំបូងថែមទាំងប្រកាសថានឹងចេញសេចក្តីសម្រេចផ្សេងទៀត "ក្នុងចន្លោះពេលនេះ"[29]។

៣៥. អាស្រ័យហេតុនេះ នៅពេលចេញសេចក្តីសម្រេចរងការជំទាស់ ក្នុងបរិបទនេះ (និងដោយប្រកាសថានឹងចេញសេចក្តីសម្រេចផ្សេងទៀតស្រដៀងគ្នានេះ) អង្គជំនុំជម្រះសាលាដំបូងពិតជាបានប្រព្រឹត្តកំហុសអង្គច្បាប់ ដែលនាំឲ្យមោឃភាពសេចក្តីសម្រេចដែលត្រូវបានប្តឹងសាទុក្ខនេះ និងបន្ថែមទៅលើកំហុសផ្សេងៗទៀតរបស់អង្គជំនុំជម្រះសាលាដំបូង។ លើសពីនេះទៅទៀត សេចក្តីសម្រេចដែលត្រូវបានប្តឹងសាទុក្ខនេះ មានកំហុសស្តែងចេញពីការប្រើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបង្កព្យសនកម្មដល់ម្ចាស់បណ្តឹងសាទុក្ខ និងភាគីផ្សេងទៀត ហើយក៏ត្រូវធ្វើមោឃភាពផងដែរ ដោយសារហេតុផលនេះ។

## ២. កំហុសស្តែងចេញពីការប្រើឆន្ទានុសិទ្ធិដែលបង្កឲ្យមានព្យសនកម្ម

៣៦. នៅក្នុងសេចក្តីសម្រេចរងការជំទាស់ អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុសទីមួយ ដោយសារខ្លួនយល់ឃើញថា ការបន្តសវនាការលើអង្គសេចក្តី ("ក្នុងពេលទន្ទឹងរង់ចាំ" សេចក្តីសម្រេចថ្មីលើការបំបែកកិច្ចដំណើរការនីតិវិធី) អាចធ្វើទៅបាន ដោយមិនបង្កព្យសនកម្មដល់ភាគីនោះឡើយ។

៣៧. ជាការពិត "ដំណាក់កាលអន្តរកាល" របៀបនេះ ធ្វើឲ្យមានឡើងវិញនូវព្យសនកម្មដែលទទួលរង និងត្រូវបានកត់សម្គាល់ដោយអង្គជំនុំជម្រះតុលាការកំពូល ខណៈដែលមិនមានការធានាបាននូវភាពយុត្តិធម៌ និងសច្ចភាពផ្លូវច្បាប់។

៣៨. អង្គជំនុំជម្រះសាលាដំបូងប្រព្រឹត្តកំហុសទីពីរ ដោយសារខ្លួនយល់ឃើញថា ការបន្តសវនាការលើអង្គសេចក្តី តាមរយៈការស្តាប់សក្ខីកម្មអ្នកជំនាញ Philip SHORT និង Elisabeth BECKER អាចធ្វើទៅបាន ដោយមិនបង្កព្យសនកម្មដល់ភាគីនោះឡើយ។

---

[29] សេចក្តីសម្រេចរងការជំទាស់ ឃ្លាចុងក្រោយ៖ *"សេចក្តីណែនាំអន្តរកាលផ្សេងទៀតនឹងចេញជូនភាគី ក្នុងពេលសមស្របខាងមុខ"*។

៣៩. នៅក្នុងអ៊ីមែលរងការជំទាស់នេះ មន្ត្រីច្បាប់ជាន់ខ្ពស់បានបញ្ជាក់ជូនភាគីថា៖ *"ស្របតាមសេចក្តីណែនាំមុនៗរបស់អង្គជំនុំជម្រះសាលាដំបូង អ្នកជំនាញទាំងពីរអាចត្រូវបានសួរដេញដោលលើសំណុំរឿង ០០២ ទាំងមូលតែម្តង ផ្អែកលើការដឹងឮរបស់អ្នកជំនាញ ហើយភាគីត្រូវបានជំរុញឱ្យកម្រិតការសួរសំណួរត្រឹមតែអង្គហេតុនៃសំណុំរឿង ០០២/០១។ ក៏ប៉ុន្តែ អង្គជំនុំជម្រះសាលាដំបូងនឹងមិនស្តាប់សក្ខីកម្មបុគ្គលផ្សេងទៀតដែលបានគ្រោងទុក មុនពេលចេញសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល"*[30]។

៤០. ភាពខ្ជាប់ខ្ជួនតែមួយគត់របស់អង្គជំនុំជម្រះសាលាដំបូង គឺឥរិយាបថផ្ទុយគ្នា និងចរិតលក្ខណៈមិនអាចយល់បាននៃសេចក្តីសម្រេចរបស់ខ្លួន។

៤១. យ៉ាងណាមិញ អង្គជំនុំជម្រះសាលាដំបូងសម្រេចផ្ទុយគ្នាលើវិសាលភាពនៃការស្តាប់សក្ខីកម្មអ្នកជំនាញ។ ឧទាហរណ៍ នៅថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងបានជម្រាបភាគីថានឹងស្តាប់សក្ខីកម្មអ្នកជំនាញទាំងនេះ *"លើរាល់បញ្ហាទាំងឡាយដែលពួកគាត់មានលទ្ធភាពអាចឆ្លើយបាន ក្នុងក្របខ័ណ្ឌនៃសំណុំរឿង ០០២ ទាំងមូល"*។ លោក Philip SHORT នឹងផ្តល់សក្ខីកម្មរយៈពេល ៦ ថ្ងៃ ហើយលោកស្រី Elisabeth BECKER នឹងផ្តល់សក្ខីកម្មរយៈពេល ៥ ថ្ងៃ។ ពេលនោះ ការស្តាប់សក្ខីកម្មអ្នកជំនាញទាំងពីរត្រូវបានគ្រោងធ្វើ នៅខែ តុលា ឆ្នាំ ២០១២[31]។

៤២. នៅថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៣ ក្រោយពីលើកពេលស្តាប់សក្ខីកម្មអ្នកជំនាញទាំងពីររូប ដោយសារតែស្ថានភាពសុខភាពរបស់លោក អៀង សារី មិនអំណោយផល និងដោយសារតែមានភាពយឺតយ៉ាវនៃកិច្ចដំណើរការនីតិវិធីទាំងមូល អង្គជំនុំជម្រះសាលាដំបូងបាន *"កាត់បន្ថយរយៈពេលស្តាប់សក្ខីកម្មដែលបានគ្រោងទុកពីដំបូង"* មកត្រឹមបួនថ្ងៃ សម្រាប់អ្នកជំនាញម្នាក់ៗ ក្នុងនោះអង្គជំនុំជម្រះសាលាដំបូងនឹងសួរសំណួររយៈពេលមួយថ្ងៃ។ ទន្ទឹមនឹងនោះ អង្គជំនុំជម្រះសាលាដំបូងបាន *"ជំរុញឱ្យភាគីកម្រិតការសួរសំណួរត្រឹមតែចំណុចណាដែលពាក់ព័ន្ធនឹងសំណុំរឿង ០០២/០១*

[30] សេចក្តីសម្រេចរងការជំទាស់ ត្រេទីមួយ។

[31] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១២ ស្តីពីព័ត៌មានបច្ចុប្បន្នភាពទាក់ទិននឹងការកំណត់កាលបរិច្ឆេទស្តាប់សក្ខីកម្មអ្នកជំនាញដែលភាគីបានស្នើសុំ ឯកសារ E172/24។

*ប៉ុណ្ណោះ"*[32]។

៤៣. តាមពិត ការកាត់បន្ថយចំនួនថ្ងៃសួរសំណួរ អមដោយ "ការជំរុញ" ឲ្យកម្រិតត្រឹមតែសំណុំរឿង ០០២/០១ ស្មើនឹងបង្ខំឲ្យភាគីកម្រិតការសួរសំណួរត្រឹមតែវិសាលភាពនៃសំណុំរឿង ០០២/០១។

៤៤. ដើម្បីជាការបញ្ជាក់អំពីស្មារតីនៃជំហររបស់ខ្លួន នៅថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធសំណើរបស់មេធាវីការពារក្តីលោក នួន ជា សុំដាក់ពិភាក្សាដេញដោលនូវឯកសារថ្មី សម្រាប់សួរលោក Philip SHORT និងលោកស្រី Elisabeth BECKER ដោយសំអាងហេតុថា *"ឯកសារថ្មីទាំងនេះមិនមានភាពពាក់ព័ន្ធជាមួយអង្គហេតុ ដែលបានប្តឹងមកអង្គជំនុំជម្រះសាលាដំបូង ក្នុងក្របខ័ណ្ឌនៃសំណុំរឿង ០០២/០១"* ឬ *"ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍មិនមែនជាបទចោទ ដែលបានប្តឹងមកអង្គជំនុំជម្រះសាលាដំបូងឡើយ"*[33]។

៤៥. ផ្ទុយទៅវិញ ឯកសារទាំងនេះមានភាពពាក់ព័ន្ធ ក្នុងករណីអ្នកជំនាញអាចត្រូវបានស្តាប់សក្ខីកម្ម *"លើរាល់បញ្ហាទាំងឡាយ ដែលពួកគាត់មានលទ្ធភាពអាចឆ្លើយបាន ក្នុងក្របខ័ណ្ឌនៃសំណុំរឿង ០០២ ទាំងមូល"*[34]។

៤៦. នៅថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៣ នៅក្នុងសេចក្តីសម្រេចរងការជំទាស់ អង្គជំនុំជម្រះសាលាដំបូងនៅតែបដិសេធថា ខ្លួនមិនបានបង្ខំឲ្យភាគីត្រៀមរៀបចំ សម្រាប់ការផ្តល់សក្ខីកម្មរបស់អ្នកជំនាញទាំងនេះ ដោយកម្រិតត្រឹមតែវិសាលភាពនៃសំណុំរឿង ០០២/០១ នោះទេ។ អង្គជំនុំជម្រះសាលា

---

[32] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៣ ស្តីពីការកំណត់កាលបរិច្ឆេទស្តាប់សក្ខីកម្មសាក្សី និងអ្នកជំនាញ សម្រាប់ដើមឆ្នាំ ២០១៣ ឯកសារ E236/4 (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[33] អនុស្សរណៈរបស់អង្គជំនុំសាលាដំបូង ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៣ ស្តីពីចម្លើយតបទៅនឹងសំណើ តាមវិធាន ៨៧(៤) សុំដាក់ឯកសារថ្មីទៅក្នុងសំណុំរឿង ពាក់ព័ន្ធនឹងសក្ខីកម្មរបស់សាក្សី François PONCHAUD និង Sydney SCHANBERG (E243) ព្រមទាំងអ្នកជំនាញ Philip SHORT (E226, E226/1 និង E230) និង Elizabeth BECKER (E232 និង E232/1), ឯកសារ E260 កថាខណ្ឌ ៤ និងកថាខណ្ឌ ៨។

[34] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១២ ស្តីពីព័ត៌មានបច្ចុប្បន្នភាពទាក់ទិននឹងការកំណត់កាលបរិច្ឆេទស្តាប់សក្ខីកម្មអ្នកជំនាញដែលភាគីបានស្នើសុំ ឯកសារ E172/24។

ដំបូងក៏បានបដិសេធផងដែរនូវផលវិបាកដែលបង្កឲ្យមានព្យសនកម្ម ដោយសារតែការរក្សាការស្តាប់សក្ខីកម្មទុកដដែល នៅដំណាក់កាលមិនច្បាស់លាស់នៃនីតិវិធី។

៤៧. វិសាលភាពនៃសំណុំរឿង ០០២/០១ ត្រូវបានធ្វើមោឃភាព។ ការជំនុំជម្រះក្តីថ្មីត្រូវបានប្រកាស ដោយមិនបានកំណត់ ឬបញ្ជាក់អំពីវិសាលភាពឲ្យបានច្បាស់ ហើយវិសាលភាពនៃការជំនុំជម្រះក្តីជាយថាហេតុខាងមុខបន្តបន្ទាប់ទៀតក៏មិនបានកំណត់ឲ្យបានច្បាស់លាស់។ ហេតុនេះ សំណួរគ្មានចម្លើយជាច្រើន ភាពមិនច្បាស់លាស់ និងភាពមិនអាចស្មានដឹង រារាំងដល់លទ្ធភាពរបស់ភាគីក្នុងការត្រៀមរៀបចំខ្លួន។

៤៨. តើត្រៀមរៀបចំសួរសំណួរយ៉ាងដូចម្តេច ខណៈដែលភាពពាក់ព័ន្ធមិនទាន់បានកំណត់ផងនោះ? តើដឹងច្បាស់យ៉ាងដូចម្តេចថា នៅពេលភាពពាក់ព័ន្ធនៃសំណួរត្រូវបានកំណត់ យើងអាចសួរសំណួរទាំងនោះបាន? តើផ្នែកណាខ្លះនៃសក្ខីកម្មនឹងត្រូវបានចៅក្រមចាត់ទុកថាមានភាពពាក់ព័ន្ធ? តើផ្នែកនៃសក្ខីកម្មទាំងនោះត្រូវបានប្រើប្រាស់ជាប្រយោជន៍យ៉ាងដូចម្តេច ក្នុងករណីមានការជំនុំជម្រះក្តីច្រើនវគ្គ[35]? តើណែនាំកូនក្តីយ៉ាងដូចម្តេច ចំពោះយុទ្ធសាស្ត្រដែលត្រូវប្រកាន់យក?

៤៩. ដូច្នេះ សេចក្តីសម្រេចស្តាប់សក្ខីកម្មអ្នកជំនាញទាំងពីររូប ក្នុងល័ក្ខខ័ណ្ឌបែបនេះ មិនសមហេតុផលនោះទេ។

៥០. ទោះបីជាសេចក្តីសម្រេចនេះផ្អែកលើមូលដ្ឋានថា *"ប្រហែលជាអង្គជំនុំជម្រះនឹងបាត់បង់ឱកាស"* ក្នុងការស្តាប់សក្ខីកម្មពួកគាត់ទាំងស្រុងតែម្តង ប្រសិនបើមិនអាចស្តាប់សក្ខីកម្មអ្នកជំនាញទាំងនេះទៅតាមកាលបរិច្ឆេទដូចបានកំណត់នាពេលបច្ចុប្បន្ននេះទេ[36] យុត្តិកម្មនេះផ្ទុយនឹងសេចក្តីសម្រេចដដែលនេះ ដែលបដិសេធការស្តាប់សក្ខីកម្មសាក្សីចាស់ជរា នាពេលឆាប់ៗខាងមុខ លើសំណុំរឿង

[35] កង្វល់របស់មេធាវីការពារក្តីលោក អៀង សារី ផ្ញើជូនអង្គជំនុំសាលាដំបូង តាមរយៈលិខិតផ្ញើជូនលោកស្រី Susan LAMB នៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣ កម្មវត្ថុ៖ *"សំណុំសុំការបំភ្លឺ និងសេចក្តីណែនាំ ពាក់ព័ន្ធនឹងសក្ខីកម្ម ដែលអាចចេញហួសពីវិសាលភាពនៃការជំនុំជម្រះក្តី"*។ លិខិតនេះមានភ្ជាប់ជាឧបសម្ព័ន្ធ។

[36] អនុស្សរណៈទី ២ ស្តីពីសវនាការលើការបំបែកកិច្ចដំណើរការនីតិវិធី កថាខណ្ឌ ៣ iii)។

០០២ ទាំងមូល[37]។ ជាការពិត លទ្ធភាពបាត់បង់ឱកាសក្នុងការស្តាប់សក្ខីកម្មសាក្សីចាស់ជរាទាំងនេះរឹតតែច្រើនទៅទៀត ពីព្រោះថា ខុសពីអ្នកជំនាញ Philip SHORT និង Elisabeth BECKER សាក្សីចាស់ជរាអាចនឹងអសម្បទាទាំងស្រុងភ្លាមៗ ក្នុងការមកផ្តល់សក្ខីកម្ម។

៥១. យុត្តិកម្មនេះ ក៏ផ្ទុយនឹងការបង្ខំឲ្យភាគីកម្រិតការស្តាប់សក្ខីកម្មអ្នកជំនាញទាំងនេះត្រឹមសំណុំរឿង ០០២/០១ ដោយសារតែវិសាលភាពនៃសំណុំរឿង ០០២/០១ ត្រូវបានធ្វើមោឃភាព។

៥២. ជារួម ម្ចាស់បណ្តឹងសាទុក្ខស្ថិតក្នុងភាពងងឹតសូន្យឈឹង និងមិនអាចត្រៀមលក្ខណៈការពារខ្លួនបាន ដោយសារមិនអាចប្រមើលមើលបាន ក្នុងរយៈពេលខ្លី មធ្យម និងវែង និងគ្មានសច្ចភាពផ្លូវច្បាប់ទាល់តែសោះ។ ភាពច្បាស់លាស់តែមួយគត់ គឺថាម្ចាស់បណ្តឹងសាទុក្ខនឹងស្ថិតចំពោះមុខនិដ្ឋិតកម្មម្តងទៀត ប្រសិនបើអ្នកជំនាញទាំងនេះត្រូវបានស្តាប់សក្ខីកម្ម ក្នុងល័ក្ខខ័ណ្ឌបែបនេះ។ ព្យសនកម្មដែលម្ចាស់បណ្តឹងសាទុក្ខទទួលរង នឹងមិនអាចជួសជុលបាន ប្រសិនបើខ្លួនមិនអាចសួរដេញដោលអ្នកជំនាញទាំងនេះជាថ្មីម្តងទៀត ដោយសារហេតុផលណាមួយនោះ។

៥៣. ដូច្នេះ សេចក្តីសម្រេចរងការជំទាស់ មានកំហុសស្តែងចេញពីការប្រើឆន្ទានុសិទ្ធិ ដែលបង្កឲ្យមានព្យសនកម្មធ្ងន់ធ្ងរដល់ម្ចាស់បណ្តឹងសាទុក្ខ។ សេចក្តីសម្រេចនេះត្រូវតែធ្វើមោឃភាព។

៥០. **អាស្រ័យហេតុនេះ** មេធាវីការពារក្តីលោក ខៀវ សំផន ស្នើអង្គជំនុំជម្រះតុលាការកំពូលមេត្តា៖

- **ចាត់ការជាបន្ទាន់ ឬ បន្ទាប់ឲ្យផ្អាក** កិច្ចដំណើរការនីតិវិធីលើអង្គសេចក្តី រហូតដល់ពេលចេញសេចក្តីសម្រេចលើបណ្តឹងសាទុក្ខនេះ
- **ប្រកាស** ទទួលយកបណ្តឹងសាទុក្ខនេះ
- **ធ្វើមោឃភាព** សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង។

[37] ប្រតិចារឹកសវនាការ ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៣ (សំណៅព្រាង) ទំព័រ ១៧ បន្ទាត់ ៧-៩, សេចក្តីសម្រេចរងការជំទាស់ត្រង់ទីមួយ។

បណ្តឹងសាទុក្ខភ្លាមៗរបស់មេធាវីការពារក្តីលោក ខៀវ សំផន ប្រឆាំងនឹងសេចក្តីសម្រេច
ចេញតាមរយៈអ៊ីម៉ែលរបស់លោកស្រី Susan LAMB នៅថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៣

| | | | |
|---|---|---|---|
| | មេធាវី គង់ សំអុន | ទីក្រុងភ្នំពេញ | *[ហត្ថលេខា]* |
| | មេធាវី Anta GUISSÉ | ទីក្រុងប៉ារីស | *[ហត្ថលេខា]* |
| | មេធាវី Arthur VERCKEN | ទីក្រុងប៉ារីស | *[ហត្ថលេខា]* |
| | មេធាវី Jacques VERGÈS | ទីក្រុងប៉ារីស | *[ហត្ថលេខា]* |
| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |